**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**អគ្គនាយកដ្ឋានយោធសេវា**

**នាយកដ្ឋានព័ត៌មាន**

លេខ:....../.............

# សេចក្តីប្រកាសជូនដំណឹង

តបតាមការអញ្ជើញរបស់សមាគមចិនសម្រាប់វិទ្យាសាស្ត្រយោធា (CAMS) និងវិទ្យាស្ថានសិក្សាយុទ្ធសាស្ត្រអន្តរជាតិរបស់ចិន (CIISS) **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** នៃព្រះរាជាណាចក្រកម្ពុជានឹងដឹកនាំគណប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិទៅចូលរួមវេទិការសៀងសានលើកទី៧ ( 7th Xiangshan Forum ) ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ នៅទីក្រុងប៉េកាំង សាធារណៈរដ្ឋប្រជាមានិតចិន។

នេះជាវេទិកាប្រចាំឆ្នាំសម្រាប់កិច្ចសន្ទនាកម្រិតខ្ពស់ស្តីពីបញ្ហាសន្តិសុខនិងការពារជាតិនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដោយវេទិកាសៀងសានអញ្ជើញថ្នាក់ដឹកនាំការពារជាតិ និងមេដឹកនាំយោធាអ្នកតំណាងអង្គការអន្តរជាតិ អតីតមន្ត្រីរដ្ឋាភិបាល និងមន្ត្រីយោធាអ្នកជំនួញនិងសាស្ត្រាចារ្យមកពីបណ្តាប្រទេសក្នុងអាស៊ីប៉ាស៊ីហ្វិក និងតំបន់ពាក់ព័ន្ធផ្សេងៗទៀត ។ វេទិកានេះមានគោលដៅពិភាក្សាអំពីការអភិវឌ្ឍផ្នែកសន្តិសុខ បញ្ហាក្តៅមួយចំនួនពង្រឹងការផ្លាស់ប្តូរ កិច្ចសហប្រតិបត្តិការ និងចូលរួមចំណែកលើសន្តិភាព និងស្ថិរភាពក្នុងតំបន់។

ផ្តោតទៅលើទិសស្លោក " ការលើកកម្ពស់កិច្ចសន្ទនា និងសហប្រតិបត្តិការសន្តិសុខកសាងគំរូទំនាក់ទំនងអន្តរជាតិថ្មី " វេទិកាសៀងសានលើកទី៧ នេះនឹងដោះស្រាយបញ្ហានានានៃតួនាទីយោធាក្នុងអភិបាលកិច្ចសកល ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការនៃភាពប្រឈម សន្តិសុខអាស៊ីប៉ាស៊ីហ្វិកថ្មីដូចជា កិច្ចសហប្រតិបត្តិការសន្តិសុខលម្ហសមុទ្រ ការគំរាមកំហែង និងឆ្លើយតបភេរវកម្មអន្តរជាតិ។ មេដឹកនាំចិនមកពីគណៈកម្មាធិការយោធាមជ្ឈិមក្រសួងការពារជាតិនិងក្រសួងការបរទេសនឹងត្រូវចូលរួមវេទិកានេះ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ៩៣ ឆ្នាំ២០១៦